# របាយការណ៍ប្រចាំខែមិថុនា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

## I. ស្ថានភាពការងាររបស់មន្ទីរ ÷

### 1. ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷

❷ ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៣ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០២ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ-ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

#### 1.1. ចំនួនមន្ត្រីរាជការ

| | |
|---|---|
| – សរុប | ÷ ២០នាក់ |
| – ប្រុស | ÷ ១៦នាក់ |
| – ស្រី | ÷ ០៤នាក់ |
| – ចំនួនប្រពន្ធមន្ត្រីរាជការ | ÷ ១១ នាក់ |
| – ចំនួនកូន | ÷ ១៩ នាក់ |
| – អវត្តមាន | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចូល | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចេញ | ÷ ១នាក់ |
| – ចំនួនមន្ត្រីរាជការក្របខ័ណ្ឌថ្មី | ÷ គ្មាន |

- ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ ÷ គ្មាន
- ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ គ្មាន
- ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន
- ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្តែត ÷ ២នាក់
- ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
- ចំនួនមន្ត្រីរាជការសហការជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷០៦នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ឈុន ប៊ុនថេង | ប | ប្រធានការិយាល័យ | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៤ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | ឃិត សុធារ៉ា | ប | មន្ត្រី | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៦ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |

1.2. **ការងារលិខិតចេញ-ចូល**

បានធ្វើចរាចរលិខិតស្នាម ក្នុងនោះមាន÷

–បានចូលរួមចេញលិខិតបេសកកម្មចំនួន ÷១៦លើក

–បានចេញលិខិតទៅស្ថាប័ននានា និងក្នុងមន្ទីរចំនួន ÷២០លើក

–បានទទួលលិខិតចូលពីគ្រប់ស្ថាប័ននានាចំនួន ÷១០ច្បាប់

–លិខិតផ្សេងៗចំនួន ÷០១ច្បាប់

1.3. **ការងាររដ្ឋបាល និងបុគ្គលិក**

–បានរៀបលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកផ្សេងៗជូនមន្ត្រីរាជការចេញដោយមន្ទីរចំនួន÷០២ច្បាប់

–បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷០៥លើក

–បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷០៨លើក

– បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷០៣លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

–បានរៀបចំលិខិតផ្ដាច់បៀវត្សមន្ត្រីផ្ទេរចេញ

–បានរៀបចំបើកប្រាក់បៀវត្សប្រចាំខែមិថុនា ឆ្នាំ២០១៥

–បានរៀបចំប្រាកបៀវត្សជូនមន្ត្រីជាប់កិច្ចសន្យា។

1.5. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

\+ **ប្រភពថវិការដ្ឋផ្ដល់**

- **ថវិកាអនុម័តឆ្នាំ២០១៥** ចំនួន **៤៤០.៥០០.០០០៛០០**
  - ប្រាក់ជំពូក ៦០ ចំនួន ៧០.០០០.០០០៛០០
  - ប្រាក់ជំពូក ៦១ ចំនួន ១៧១.៥០០.០០០៛០០
  - ប្រាក់ជំពូក ៦៤ ចំនួន ១៩៨.០០០.០០០៛០០
  - ប្រាក់ជំពូក ៦៣ ចំនួន ១.០០០.០០០៛០០
- **ថវិកាចំណាយសម្រាប់ខែមិថុនា ឆ្នាំ២០១៥** ចំនួន **២១.៥៥៧.៥៦០៛០០**
  - ប្រាក់ជំពូក ៦០ ចំនួន ៥,៦៦១,៦០០៛
  - ប្រាក់ជំពូក ៦៤ ចំនួន ១៥,៨៩៥,៩៦០៛
  - ប្រាក់ជំពូក ៦៣ គ្មាន

2. **ការងារផែនការ និងស្ថិតិ** ÷

–ធ្វើរបាយការណ៍ផែនការឆ្នាំ ២០១៤-២០១៨ ដាក់ជូននាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងអភិវឌ្ឍន៍ជនបទ

–ធ្វើរបាយការណ៍ផែនការឆ្នាំ ២០១៥-២០១៧ ដាក់ជូនមន្ទីរ ផែនការខេត្ត។

3. **ការងារអធិការកិច្ច និង សវនកម្ម÷**

–គ្មានសកម្មភាព

4. **ការងារទំនាក់ទំនងសាធារណ:**

–គ្មានសកម្មភាព

II. **សកម្មភាពការងារតាមវិស័យ ÷**

1. **សកម្មភាពផ្លូវជនបទ**

– ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០១៥ ក្រុមការងារបច្ចេកទេសមន្ទីរ និងក្រសួងអភិវឌ្ឍន៍ជនបទដឹកនាំដោយលោក គង់ ភឿន ប្រធាននាយកដ្ឋានផ្លូវជនបទបានចុះសិក្សាផ្លូវក្រាលក្រួសក្រហម ០១ ខ្សែប្រវែង ១១.៥០០គម ពីភូមិមរតកតេជោ ទៅភូមិស្រែ ឃុំរំដោះស្រែ ស្រុកជាំក្សាន្ត

- ថ្ងៃទី ២៥-២៨ ខែឧសភា ឆ្នាំ២០១៥ ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា ដើម្បីជ្រើសរើសអាទិភាពខ្សែផ្លូវធ្វើការថែទាំជាលក្ខណៈខួបនិងប្រចាំសម្រាប់ឆ្នាំ២០១៦ នៅក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី ០៥-០៧ ខែឧសភា ឆ្នាំ២០១៥ ចុះត្រួតពិនិត្យទីតាំងផ្លូវ ២៤.៦០០ម៉ែត្រ នៅស្រុកជាំក្សាន្ត ជាមួយនាយកដ្ឋានផ្លូវលំជនបទ
- ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៥ ចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវក្រាលក្រួសក្រហមចំនួន ១ខ្សែ ពីភូមិពោធិ ទៅភូមិអូរកក់ប្រវែង ៨៣២២ម៉ែត្រ និងសំណង់សិល្បះការចំនួន ១០ កន្លែង ស្ថិតនៅភូមិពោធិ ឃុំពោធិ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ អនុវត្តដោយមន្ទីរអភិវឌ្ឍន៍ជនបទ របស់គម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែមធនាគារអភិវឌ្ឍអាស៊ី (ADB) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃ គណអភិបាលខេត្តព្រះវិហារ ដោយមានការចូលរួមពីប្រជាពលរដ្ឋ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និងមន្ទីរជំនាញជុំវិញខេត្ត សរុបចំនួន ៤០០ នាក់ ។

2. **សកម្មភាពការងារចុះស្រង់ទិន្នន័យ**

   –ថ្ងៃទី ០២-០៤ ខែមិថុនា ឆ្នាំ២០១៥ ចុះសិក្សានិងប្រមូលទិន្នន័យផ្លូវ ២៥ គីឡូម៉ែត្រ នៅស្រុករវៀង។

3. **ការងារធ្វើបច្ចុប្បន្នភាព**

   –គ្មានសកម្មភាព។

4. **ការងារផ្គត់ផ្គង់ទឹកជនបទ**

   –បានរៀបចំធ្វើបច្ចុប្បន្នភាពនូវទិន្នន័យការងារផ្គត់ផ្គង់ទឹកស្អាតជនបទ ជូននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

   –ថ្ងៃទី ២៥-២៦ ខែ ឧសភា ឆ្នាំ២០១៥ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ បាន សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការកសាងផែនការសកម្មភាពសម្រាប់ថ្នាក់ខេត្តរាជធានី ស្តីពីការផ្គត់ផ្គង់ទឹក និងលើកកម្ពស់ អនា ម័យជនបទ ឆ្នាំ២០១៤-២០១៨ ក្រោមអធិបតីភាព ឯកឧត្តម អ៊ុន ចាន់ដា អភិបាលរងខេត្ត និងការចូលរួមពី មន្ត្រីប្រតិភូនាយកដ្ឋានសុខភាពជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត មន្ត្រីថ្នាក់ ស្រុក ថ្នាក់ឃុំ អង្គការដៃគូអភិវឌ្ឍន៍ សរុបចំនួន ៥២នាក់ ។

5. **ការងារថែទាំសុខភាពជនបទ**

   –នៅថ្ងៃទី ១០-១២ ខែមិថុនា ឆ្នាំ២០១៥ នៅសណ្ឋាគារសែនជូរី ខេត្តសៀមរាប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ស្តីពីការបន្ស៊ីផែនការសកម្មភាពជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការងារផ្គត់ផ្គង់ទឹក ស្អាតនិងលើកកម្ពស់អនាម័យជនបទឆ្នាំ ២០១៤-២០១៨ ក្រោម

អធិបតីភាព ឯកឧត្តម ទ្រី មេង រដ្ឋលេខាធិ ការតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ជា សុផារ៉ា រដ្ឋមន្រ្តីក្រសួងអភិវឌ្ឍន៍ជនបទ។ អញ្ជើញចូលរួម ÷ លោកប្រធាន-អនុប្រធាននាយកដ្ឋានជំនាញទាំងពីរ (ផ្គត់ផ្គង់ទឹកជនបទ និងថែទាំសុខភាពជនបទ) លោក -លោកស្រីជា ប្រធាន-អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទទាំង២៥រាជធានីខេត្ត និងអង្គការដៃគូអភិវឌ្ឍន៍សរុបចំនួន ៦៥នាក់ រៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ ។

6. **ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ ÷**

–គ្មានសកម្មភាព។

7. **ការងារអភិវឌ្ឍន៍សហគមន៍÷**

–បានសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ និងអាជ្ញាធរភូមិបានចំនួន១១ភូមិ ២ឃុំ នៃស្រុកសង្គមថ្មី ក្នុងការរៀបចំជ្រើសរើសបំពេញបន្ថែមនូវសមាសភាព គ.អ.ភ ដើម្បីអោយស្របតាម សារាចរណែនាំស្តីពីការអនុវត្ត ប្រកាសអន្តរក្រសួងលេខ២៣៩១ប្រក ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០ របស់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ និងរដ្ឋមន្រ្តីក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)។

8. **ការងារសេដ្ឋកិច្ចជនបទ÷**

–គ្មានសកម្មភាព។

9. **ការងារជនជាតិដើមភាគតិច÷**

–ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ខេត្តស្តីពី Trade SWAp, EIP CEPDEP1 & CEPDEP2 ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលសម្រេច និងផលប៉ះពាល់ក្រោមកម្មវិធីសមាហ រណកម្ម នៅខេត្តរតនៈគីរី

–ថ្ងៃទី ០២-០៥ ខែមិថុនា ឆ្នាំ ២០១៥ ចូលរួមដំណើរទស្សនៈកិច្ចសិក្សាស្តីការអនុវត្តអនាម័យល្អដោយខ្លួនឯង នៅតាមសហគមន៍ CLTSនៅខេត្តកំពតដោយមានការចូលរួមពីៈ តំណាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត០៣រូប តំណាងអភិបាលស្រុកគូលែន០១រូប តំណាងក្រុមប្រឹក្សាឃុំថ្មីស្រុកគូលែន០១រូប តំណាងសហគមន៍០៦ភូមិ ចំនួន១១នាក់ លោកនាយកនាយិកាសាលាបឋមសិក្សា ០៣នាក់ តំណាងអង្គការទស្សនៈពិភពលោក០១ នាក់ដោយមានការគាំទ្រដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកគូលែនខេត្តព្រះវិហារ។

10. **ការងារយេនឌ័រ÷**

–គ្មានសកម្មភាព។

11. **ការងារ NGOs÷**

-នៅថ្ងៃទី ០២-០៥ ខែ មិថុនា ឆ្នាំ ២០១៥ បានដឹកនាំតំណាងអាជ្ញាធរ (ថ្នាក់ស្រុក ឃុំ ភូមិ) នាយកសាលា ០៣ សាលា និងជនបង្គោលអនាម័យភូមិទាំង០៦ភូមិ ឃុំថ្មី ស្រុកគូលែន សរុបចំនួន ២០នាក់ ដើម្បីចូលរួមដំណើរ ទស្សនកិច្ចសិក្សាដកបទពិសោធន៍ ត្រួតពិនិត្យស្ថិតិសហគមន៍ដឹកនាំអនុវត្តអនាម័យដោយខ្លួនឯង (CLTS) ដែលគេបានទទួលជោគជ័យ នៅក្នុងស្រុកទឹកឈូ ខេត្តកំពត គាំទ្រដោយអង្គការទស្សនៈពិភពលោក។

12. **គម្រោង / កម្មវិធី ៖**

12.1. **គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញទានបន្ថែម** (ADB)

-ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៥ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៨.៣២២ម៉ែត្រ និងសំណង់ សិល្បៈការចំនួន ១១ កន្លែង ក្នុងនោះលូប្រអប់ចំនួន ០២កន្លែង លូមុខបី ០១កន្លែង លូមុខបី ០៣កន្លែង និងលូទោលចំនួន ០៥កន្លែង នៅឃុំពោធិ ស្រុកត្បែងមានជ័យ។ លទ្ធផលសម្រេចបានក្រុមហ៊ុនបានក្រាលក្រួសក្រហមបាន ប្រវែង ៨.៣២២ម ស្មើនឹង ១០០%

-ថ្ងៃទី ០៩-១០ ខែមិថុនា ឆ្នាំ២០១៥ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៨.៣២២ម៉ែត្រ ពីភូមិ កំពេញទៅភូមិយាង ស្រុកជាំក្សាន្ត លទ្ធផលសម្រេចបានក្រុមហ៊ុនអនុវត្ត ៤០%។

12.2. **កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍ (គាំទ្រថវិកាដោយ** UNICEF)

-ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ក្រុមការងារទឹកស្អាត និងអនាម័យរបស់មន្ទីរបានរៀបចំសំណើផែនការសកម្មភាពថវិកាសម្រាប់អនុវត្តក្នុងត្រីមាសទី ២ ឆ្នាំ ២០១៥ ជូនអ្នកសម្របសម្រួលថ្នាក់ជាតិ MRD/CU-Unicef ។

12.3. **គម្រោងអភិវឌ្ឍន៍តាមបណ្តោយព្រំដែនខាងលិច ខាងជើង៖**

-ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០១៥ ក្រុមការងារបច្ចេកទេសមន្ទីរ និងក្រសួងអភិវឌ្ឍន៍ជនបទដឹកនាំដោយលោក គង់ ភឿន ប្រធាននាយកដ្ឋានផ្លូវជនបទបានចុះសិក្សាផ្លូវក្រាលក្រួសក្រហម ០១ ខ្សែ ប្រវែង ១១.៥០០គម ពីភូមិមរតកតេជោ ទៅភូមិស្រែ ឃុំរំដោះស្រែ ស្រុកជាំក្សាន្ត៕